សាធារណៈ:/Public

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

# អនុស្សរណៈអន្តរការិយាល័យ

ជូនចំពោះ: **ភាគីនានាក្នុងសំណុំរឿងលេខ០០២** កាលបរិច្ឆេទ: ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១

យោង: សំណុំរឿងលេខ ០០២/១៩ -កញ្ញា-ឆ្នាំ២០០៧-អ.វ.ត.ក-អ.ជ.ស.ដ /អ.ជ.ត.ក (០៩)

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Dec-2011, 10:01
CMS/CFO: Sann Rada

ផ្ញើពី: **គង់ ស្រីម** ប្រធានអង្គជំនុំជម្រះតុលាការកំពូល

កម្មវត្ថុ: **ការចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ (E138/1/1)**

វិធាន៨២(៦)នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះតុលាការកំពូល ត្រូវសម្រេចលើពាក្យបណ្តឹងសាទុក្ខខាងលើនេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីទទួលបានសំណុំរឿង "លើកលែងតែនៅក្នុងកាលៈទេសៈពិសេស"។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ដោយសារកាលៈទេសៈពិសេសនៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ដែលមានដូចជាការទទួលយកសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាបន្ថែម និងភាពស្មុគ្រស្មាញដែលពុំធ្លាប់មានពាក់ព័ន្ធនឹងបញ្ហាផ្នែកច្បាប់ និងការអនុវត្តជាក់ស្តែង ទើបត្រូវពន្យាកាលបរិច្ឆេទរបស់ខ្លួន ០១ (មួយ) សប្តាហ៍មកត្រឹមថ្ងៃច័ន្ទ ទី១២ ខែធ្នូ ឆ្នាំ២០១១។ ដោយហេតុថា កាលបរិច្ឆេទនេះគឺជាទិវាបុណ្យជាតិនៃព្រះរាជាណាចក្រកម្ពុជា អង្គជំនុំជម្រះតុលាការកំពូលនឹងចេញសេចក្តីសម្រេចរបស់ខ្លួននៅថ្ងៃអង្គារ ទី១៣ ខែធ្នូ ឆ្នាំ២០១១ ដោយអនុលោមតាមវិធាន ៣៩(៣) នៃវិធានផ្ទៃក្នុង។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

SUPREME COURT CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE LA COUR SUPRÊME

**គង់ ស្រីម**